# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

078.2

Novembre

ឆ្នាំទី ២៤ ខែវិច្ឆិកា លេខ ១១

ព.ស. ២៤៩៥_គ.ស. ១៩៥២

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P K - 1
1952 (11)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា — បញ្ជីរឿង — ទំព័រ


| | | |
|---|---|---|
| ព្រះពុទ្ធសាសនានៅប្រទេសចិន (តមក) .. | លោក ភិយ – ប៊ុក ........ | ៨០៣ |
| សុខកថា ...................... | ព្រះមហា ផៃ – ម៉ិល ....... | ៨១១ |

ផ្នែកអក្សរសាស្ត្រ

| | | |
|---|---|---|
| មេទ័ពចិត្តអាក្រក់ (រឿងព្រេងប្រទេសចិន) | លោក ប៊ូ - ប៉ូ ........... | ៨២២ |
| ការបណ្ដុះនិស្ស័យ (តមក) ........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង – ប៉ម ... | ៨២៧ |
| រឿងសាមកុក (តមក) ........... | ឧកញ៉ា នូ – កន .......... | ៨៣៧ |
| រឿងអារ័ក្សថ្លែងរឿងម្ភៃប្រាំ (តមក) .... | លោក ភិយ – ប៊ុក.......... | ៨៤៨ |
| រឿងស្លាប់ព្រោះជាតិ .............. | លោក គង់–លឹម ........ | ៨៥៦ |
| រឿងប៉ូលនិងវីរ៍ស៊ីនី (តមក). .......... | លោក ផេង – ជ្រីវ ........ | ៨៦៦ |

កំណត់នឹងប្រវត្តិការណ៍

| | | |
|---|---|---|
| បញ្ជីភាយនាមហៅអធិការដែលតាំងថ្មី (តមក). | ក្រសួងធម្មការ .......... | ៨៧៩ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨៣រ.០០

# សុខកថា

## ព្រះមហាផៃ-ម៉ុល វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើតខែកត្តិក ឆ្នាំជូតសំរិទ្ធិស័ក ព. ស. ២៤៩១ (១៦—១១—៤៨)

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្សការចំពោះព្រះដ៏មានព្រះភាគអរហំសម្មាសម្ពុទ្ធ វិសុទ្ធ-ញាណ ព្រមទាំងព្រះធម៌ និងព្រះសង្ឃដោយសេចក្ដីគោរព ។

អស់លោកសប្បុរសទាំងឡាយ ! ក្នុងវេលានេះ អាត្មាភាពនឹងសូមសំដែងអំពីពុទ្ធភាសិតមួយកន្លែង ឲ្យនាមបញ្ញត្តិថា "សុខកថា" ដែលព្រះសព្វញ្ញុពុទ្ធទ្រង់សំដែង មានប្រាកដនៅក្នុងគម្ពីរធម្មបទខុទ្ទក-និកាយថា:

## អត្ថម្ហិ ជាតម្ហិ សុខា សហាយា

"មិត្រសំឡាញ់ប្អូនគ្នាទាំងឡាយ តែងនាំយកសេចក្ដីសុខមកឲ្យក្នុងកាលដែលមានកិច្ចធុរៈកើតឡើង" ។

អធិប្បាយក្នុងអត្ថរសនៃពុទ្ធភាសិតនេះថា: បណ្ដាមនុស្សទាំងឡាយដែលកើតមកក្នុងសកលលោកនេះ សុទ្ធសឹងតែមានកិច្ចធុរៈប្រចាំខ្លួនគ្រប់ៗ គ្នា គ្រាន់តែប្លែកគ្នាខ្លះៗ ត្រង់ច្រើននឹងតិច ធំនឹងតូចប៉ុណ្ណោះ ។ កិច្ចធុរៈណាល្មមៗ តូចៗ បើមិនចាំបាច់ទាំពឹងរកអ្នកដទៃ ក៏គង់ធ្វើឲ្យ

សម្រេចទៅបាន, បើកិច្ចធុរៈណាធំៗ ទាល់តែរកពួកមិត្រសំឡាញ់គ្នីគ្នា ដែលនៅក្នុងខេត្តខ័ណ្ឌជនបទឬភូមិផងរបងជាមួយគ្នា ឲ្យជួយធ្វើផងទើបសម្រេចទៅបាន ។

កិច្ចធុរៈក្នុងទីនេះ ចែកចេញជាពីរផ្នែកគឺ:

១ – កិច្ចធុរៈ របស់បព្វជិត.

២ – កិច្ចធុរៈ របស់គ្រហស្ថ ។

កិច្ចធុរៈ របស់បព្វជិតតូចក៏មានធំក៏មាន កិច្ចតូចដូចយ៉ាងដេរប៉ះស្បង់ដាច់ដាចធ្លុះធ្លាយ ឬបោកលាងគក់ជ្រលក់ជាដើម, កិច្ចធុរៈប៉ុណ្ណោះអាចនឹងធ្វើតែម្នាក់ឯងទៅបាន ។ បើកិច្ចធុរៈធំៗ ដូចយ៉ាង ចីវរការ-សម័យ គឺសម័យដែលធ្វើចីវរ ឬមានអធិករណ៍ណាមួយ កើតឡើងដល់សង្ឃ ទាល់តែស្វែងរកកល្យាណមិត្ត ដែលជាអ្នកអង់អាចកងវៃស្ទាត់ជំនាញក្នុងឧបាយគ្រប់យ៉ាង ជួយធ្វើចីវរឬរម្ងាប់អធិករណ៍នោះ ឲ្យបានសម្រេច ឲ្យបានស្ងប់រម្ងាប់ទៅ កាលបើហេតុយ៉ាងនេះសម្រេចហើយទើបសេចក្ដីសុខកើតឡើងរួច បើហេតុទាំងនេះមិនទាន់បានសម្រេចទេសេចក្ដីសុខនឹងកើតឡើងពុំបានឡើយ ។ ឬកិច្ចធុរៈក្រៅពីនេះទៅទៀត ដូចយ៉ាងបដិសង្ខរណកិច្ច គឺការជួសជុលទីសេនាសនៈរបស់សង្ឃមានកុដិសាលាវិហារជាដើម ដែលទ្រុឌទ្រោមបាក់បែកគ្រាំគ្រា ឬក៏នវ-កម្មកសាងថ្មីតែម្ដង ទាល់តែរកគ្នីគ្នាដែលនៅក្នុងសង្គមជាមួយគ្នា ជួយ

ឈឺឆ្អាលចាត់ចែងឲ្យពេញបន្ទុក ទើបកិច្ចការនោះសម្រេចបាន ដោយឆាប់រហ័ស ព្រោះកិច្ចកសាងនេះ ជាកិច្ចធំ នឹងធ្វើតែម្នាក់ឯង ឲ្យបានសម្រេចដូចសេចក្ដីប្រាថ្នាមិនកើតឡើយ ។

ហេតុនេះ យើងគួរយល់ថា កិច្ចការណាដែលធំ តែប្រាសចាកពួកគ្នីគ្នាហើយ មុខជាមិនបានសម្រេចឡើយ ។ កាលបើធ្វើទៅហើយមិនបានសម្រេចដូចបំណងទេ ឈ្មោះថាបានសេចក្ដីសុខដូចម្ដេចកើត? ទាល់តែមានគេជួយខ្វល់ខ្វាយឲ្យបានសម្រេចភ្លាម ៗ ទៅ ទើបបានសេចក្ដីស្រួលសមតាមបំណង ។

អធិប្បាយអំពីកិច្ចការរបស់បព្វជិត ដោយសង្ខេបប៉ុណ្ណេះ ។ ចំណែកខាងកិច្ចការរបស់គ្រហស្ថវិញ ក៏មានសេចក្ដីស្រដៀង ៗ គ្នាដែរ ប្លែកគ្នាតែត្រង់មុខការដែលត្រូវធ្វើប៉ុណ្ណោះ ។

កិច្ចការរបស់គ្រហស្ថ មានការកាប់, គាស់, ភ្ជួរ, រាស់ស្រែចម្ការ ឬក៏សាបព្រោះបណ្ដុះ ដាំ ដក, ស្ទូង, បុក, បែន ជាដើម, កិច្ចការទាំងនេះទាល់តែពឹងពាក់ ពុំនាក់អាស្រ័យ ជនដែលនៅក្នុងភូមិផងរបងជាមួយគ្នាទៅវិញទៅមក ទើបកិច្ចការនោះសម្រេចស្រួលទាន់ចិត្តបាន ។ ឬដូចជាកសាងប្រទេសជាតិមាតុភូមិក៏ដោយ ទាល់តែស្រែកអំពាវនាវរកជន ដែលមានសញ្ជាតិជាមួយគ្នា ជួយជ្រោមជ្រែងដោយកម្លាំងកាយនឹងកម្លាំងចិត្ត ឬក៏ទ្រព្យសម្បត្តិ ឲ្យគ្រប់គ្រាន់ ទើបអាចនឹងសាងប្រទេសជាតិរបស់ខ្លួន ឲ្យឡើងដល់ថ្នាក់ ជាអារ្យប្រទេសទៅបាន ។

ខាងផ្លូវលោកប្រសិនបើចងបាច់គ្នា ជួយដោយពេញបន្ទុកហើយ សមត្ថភាពរបស់យើងប៉ុណ្ណឹងមិនអាចនឹងធ្វើបាន តោងតែយកខ្លួនទៅអែបនែបនឹងជនណាមួយ ដែលមានឈ្មោះថា "កល្យាណមិត្ត" ឲ្យផង ទើបបាន, តែមុននឹងអែបនែបពឹងពាក់ត្រូវសង្កេតមើលសិន, ឲ្យដឹងថា "នេះជាកល្យាណមិត្ត, នេះជាបាបមិត្ត" ហើយសឹមពឹងពាក់ ។

ចុះយើងមើលដូចម្ដេចនឹងស្គាល់ បើមនុស្សច្រើនម៉្លេះ?

រឿងនេះមិនជាការក្រប៉ុន្មានទេ គួរសន្និដ្ឋានថា បើទុកជាមនុស្សមានច្រើនយ៉ាងណាក៏ដោយ គង់តែយើងអាចនឹងសង្កេតដឹងច្បាស់លាស់បានដោយងាយ ៗ បើជនណាមួយដែលយើងចូលទៅរាប់រកស្និទ្ធស្នាល ស្ម័គ្រស្មាគមយកជាមិត្តហើយ គិតតែប្រយោជន៍ចំពោះខ្លួនតែម្យ៉ាង ត្រង់ការខូចខាតវិនាសប្រយោជន៍របស់មិត្តមិនគិត ចេះតែក្រសោបយកឲ្យទាន់តែបាន ឥតមានសេចក្ដីអៀនខ្មាស, មិត្តបែបនេះឈ្មោះថា មិត្តដូចជាឆ្កែចចក ឬមិត្តកាច់កគេស៊ី, ពុំគួរសេពគប់ឡើយ ។

មិត្តមួយប្រភេទទៀត បើឲ្យវត្ថុអ្វីមួយទៅហើយ សំឡឹងចាំមើលឲ្យដឹងថា តើគេឲ្យវិញឬមិនឲ្យទេ? បើគេមិនត្រឡប់ឲ្យវិញទេ ក៏បែរជាអាក់អន់ស្រពន់ចិត្តនឹងអ្នកនោះ, មិត្តបែបនេះ ឈ្មោះថា មិត្តហុតទឹកសំឡឹងកាក, ពុំគួរសេពគប់ឡើយ ។

មិត្តខ្លះទៀតបានតែមាត់ ត្រង់ខុសនិងត្រូវ ចំរើនឬវិនាសដល់មិត្តបែបណាមិនគិតទេ ឲ្យតែគេសួរចាំតែអឺអើប៉ុណ្ណោះ ដូចជាពាក្យមួយមាត់ថា “ចន្ទ អើ, អង្គារ អើ” មិត្តបែបនេះឈ្មោះថា មិត្តសៅតែពាក្យទ្រគាកស្តាប់ឈឺន, ពុំគួរសេពគប់ឡើយ ។

ឬក៏មិត្តណាមានចិត្តទ្រនឹងភោគកាច ចាក់រុកផ្តើះផ្តៀល បំផ្លិចបំផ្លាញប្រយោជន៍របស់មិត្តជាដើម, មិត្តមានប៉ុណ្ណោះជាការ បើទោះបីមានទ្រព្យសម្បត្តិ ចំណេះវិជ្ជាបរិបូណ៌ពេញលេញគ្រប់គ្រាន់ ឬមានសមត្ថភាពអង់អាចបែបណាក៏ដោយ មិនត្រូវយកខ្លួនទៅអែបខែបឡើយ ។ ព្រោះថាអាចនឹងធ្វើយើង ឲ្យកើតទុក្ខព្រួយជានិរន្តរ៍ ។ សមនឹងសុភាសិតមួយកន្លែងថា :

ទុជ្ជនោ វជ្ជនីយោវ វិជ្ជាយាលង្កតោបិ ប
មណិនាលង្កតោ សន្តោ សប្បោ កឹ ន ភយំ ករោ ។

សេចក្តីថា: មនុស្សទុជ្ជន គឺជនចិត្តអាក្រក់កក់គក់ម៉ក់ បើទុកជាប្រដាប់ដោយវិជ្ជាក៏ដោយ, គួរអ្នកទាំងឡាយវៀរកុំនៅក្បែរជិតឲ្យសោះ ដូចជាពស់មានពិស បើទុកជាប្រដាប់គាក់តែងដោយកែវមណីល្អយ៉ាងណាក៏ដោយ ( កុំចូលទៅជិតឲ្យសោះព្រោះ ) វាអាចធ្វើភ័យឲ្យកើតដល់យើងបាន ។

មិត្តដូចបានរៀបរាប់មកប៉ុណ្ណេះជាដើម កុំគប្បីបង្គិតខ្លួនប៉ះអែបនែប សមាគមជាមួយឡើយ ព្រោះមិនមែនជាកល្យាណមិត្តទេ ។

ហេតុឬឧបាយសម្រាប់សង្កេតមើលឲ្យស្គាល់ថាជាកល្យាណមិត្ត ឬមិនមែននោះ គប្បីសង្កេតមើលតាមលក្ខណៈ៧យ៉ាងដូចតទៅនេះ ៖

១— ទទ្ទំ ទទាតិ ឲ្យរបស់ដែលគេឲ្យបានដោយកម្រ, ដូចយ៉ាងរតនវត្ថុមានមាស, ប្រាក់, កែវ, កងជាដើម ដែលគេរកបានមកដោយការនឿយហត់ ឬសេចក្ដីព្យាយាមយ៉ាងម៉ឺងម៉ាត់ ឲ្យដល់ពួកមិត្តឥតស្ដាយស្រណោះ ទុកគ្រាន់ចិញ្ចឹមជីវិតឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ន ហើយនឹងធ្វើបុណ្យឲ្យទាន ដែលជាយានជំនិះសម្រាប់ជិះឆ្លងពីមនុស្សលោកនេះទៅកាន់បរលោក ។

២— ទុក្ករំ ករោតិ ធ្វើអំពើដែលគេធ្វើបានដោយកម្រ ។ បើកិច្ចរបស់មិត្តណាមួយកើតឡើង ទោះបីខ្លួនមានកិច្ចប្រញិកប្រញាប់យ៉ាងណាក៏ដោយ ស៊ូផ្អាកកិច្ចរបស់ខ្លួនទុកសិន ជួយខ្វល់ខ្វាយកិច្ចរបស់មិត្តឲ្យបានសម្រេចដូចបំណង ទើបបែរមកធ្វើការខ្លួនវិញ ។

៣— ទុក្ខមំ ខមតិ អត់ធន់ចំពោះហេតុដែលគេអត់ធន់បានដោយកម្រ ដូចជាហេតុណាមួយ ដែលកើតមកអំពីសំណាក់មិត្ត បើស្ទង់តាមទឹកចិត្តរបស់អ្នកដទៃទៅ ថាមិនអាចនឹងអត់បានទេ តែខ្លួនទំទាំមាត់សង្កត់ចិត្តអត់ធ្មត់ចំពោះហេតុនេះទាល់តែបាន ។

៤ — គុយ្ហមស្ស អាវិករោតិ ប្រាប់សេចក្ដីកំបាំងរបស់ខ្លួនដល់មិត្ត, គួរនាដូចជាគំនិតណាមួយ ដែលខ្លួនផ្ចង់គិតឡើងដឹងតែម្នាក់ឯង មិនមានអ្នកដទៃដឹងផងនោះ គំនិតយ៉ាងស្ងាត់កំបាំងបែបនេះ ក៏ស៊ូលបខ្សឹបខ្សៀវប្រាប់ដល់មិត្តមិនលាក់ទុក ។

៥ — គុយ្ហមស្ស បរិគូហតិ ជួយបិទបាំងសេចក្ដីកំបាំងរបស់មិត្ត មិនឲ្យផ្សាយចេញ, បើសេចក្ដីកំបាំងណារបស់មិត្ត ដែលខ្លួនបានដឹងហើយដោយការស្ងាត់ៗ ឬក៏កេរ្ដិ៍ឈ្មោះរបស់មិត្ត ដែលលោជាភ្លោយភ្លាត់មួយដងមួយកាលផុតទៅហើយ ក៏ជួយបិទបាំងមិនផ្សាយឲ្យចេញឆ្ងាយទៅទៀត ។

៦ — អាបទាសុ ន ជហាតិ មិនលះបង់គ្នាក្នុងគ្រាមានអន្តរាយ, ក្នុងលោកនេះមានច្រើនជាអនេក បើអន្តរាយណាមួយកើតឡើងដល់ជីវិតរបស់មិត្ត ឬមិនដល់ជីវិតទេ គ្រាន់តែមកបៀតបៀនធ្វើឲ្យពិបាកចិត្ត ដូចឈឺ, ចុក, ចាប់, កក, រួស, ក្ដៅ, រងា, ស្រៀវស្រាញ់ សង្កើសង្កាញ់ជាដើម មិនរំកិលខ្លួន ដកថយ ចេញចោលពួកមិត្តទេ ស៊ូប្រថុយនៅចាំរម្ងាប់សេចក្ដីអន្តរាយនោះ ទាល់តែស្ងប់រម្ងាប់ទើបថយចេញ ។

៧ — ព្យសនេន នាតិមញ្ញតិ មិនមើលងាយព្រោះមិត្តមានសេចក្ដីក្រីក្រ; ទោះបីមិត្តសំឡាញ់កាលពីដើមឡើយ ជាអ្នកមានទ្រព្យសម្បត្តិ

នឹងសមគ្គភាពស្មើៗគ្នា លុះមានពេលណាមួយ មិត្តម្នាក់ធ្លាក់ខ្លួនទៅជាមនុស្សក្រីក្រគោកសម្បុង ទាំងសមគ្គភាពក៏សាបរលាបចុះទៅតាមលំដាប់ បើខ្លួនទប់ជំហរនៅនឹងដែលឬក៏ជឿនឡើងពីនេះទៅទៀត ក៏គង់មិនលះបង់មិនមើលងាយមិត្តនោះឡើយ ។

ប៉ុណ្ណោះជាលក្ខណៈសម្រាប់សង្កេតមើលមិត្ត ។ បើបុគ្គលណាមួយបានប្រកបលាយលក្ខណៈដូចពោលមកខាងលើនេះ ទើបចាត់ថាជា “កល្យាណមិត្ត”, បើមិនបានគ្រប់ទាំងអស់ឲ្យបានត្រឹមតែពាក់កណ្ដាលក៏គួរសមដែរ ។

បើលក្ខណៈទាំង ៧ យ៉ាងនេះច្រើនពេក ពិបាកនឹងសង្កេត ក៏គួរសង្កេតលក្ខណៈសង្ខេបត្រឹមតែបីយ៉ាងក៏បាន ដូចបាលីតទៅនេះ ៖

អហិតេ បដិសេធោ ច ហិតេសុ ច និយោជកោ
ព្យសនេ អបរិច្ចាគោ សង្ខេបំ មិត្តលក្ខណំ ។

សេចក្ដីថា មិត្តសំឡាញ់ណាដែលហាមឃាត់គ្នា ក្នុងកម្មមិនមែនជាប្រយោជន៍ ១, មិត្តសំឡាញ់ណាដែលដឹកនាំគ្នា ក្នុងកម្មដែលមានប្រយោជន៍ ១, មិត្តសំឡាញ់ណាដែលមិនលះបង់គ្នាក្នុងគ្រាមានវិបត្តិអន្តរាយ អាចជួយគ្នាឲ្យបានតាំងនៅគង់បាន: យសស័ក្តិស្មើនឹងគ្នាដូចដើម ១; នេះជាលក្ខណៈសម្រាប់សង្កេតមិត្តយ៉ាងសង្ខេប ។

មិត្តជាបព្វជិតក្តី មិត្តជាគ្រហស្ថក្តី កាលបើប្រកបដោយលក្ខណៈ ដូចសំដែងមកខាងលើនេះ ទើបឲ្យឈ្មោះថា "កល្យាណមិត្ត" ឬ "មហាមិត្ត" ។ មិត្តបែបនេះឯង ទើបយើងគួរសេពគប់ ដើម្បីជួយជាកម្លាំង ក្នុងពេលដែលខ្លួនយើងមានកិច្ចរវល់កើតឡើងម្តង ៗ ។ ព្រោះមនុស្សយើងដែលតាំងជាក្រុម ៗ រាប់ពីភូមិមួយរហូតដល់ស្រុកមួយប្រទេសមួយ ក៏ត្រូវតែពឹងពាក់ពំនាក់អាស្រ័យគ្នា ក្នុងកិច្ចការច្រើនខ្លះតិចខ្លះដូចសំដែងមកខាងលើនេះ ។

ម្យ៉ាងទៀតបើសំដែងខាងផ្លូវលោក ដូចជាកិច្ចកសាងប្រទេសជាតិមាតុភូមិដែលជាកិច្ចផុតវិស័យមនុស្សមានចំនួនតិចនឹងធ្វើកើត ទាល់តែមានគ្នីគ្នាជាកល្យាណមិត្តជួយ ទើបធ្វើទៅបានសម្រេចតាមបំណង ។

ហេតុនេះ យើងគួរលះបង់បាបមិត្តចេញ ហើយគួរស្វែងរកសេពគប់នឹងកល្យាណមិត្ត ឬ មហាមិត្ត ព្រោះកល្យាណមិត្តមិនសូវមានទេ, ឯបាបមិត្តមានច្រើនណាស់ ។

សូមឧបមាឲ្យឃើញប្រាកដថា: ដូចជា មាស, ប្រាក់, កែវ, កង, ពេជ្រ, និល ជាដើម, ជារបស់មិនសូវមានសម្បូណ៌ ទាល់តែយើងខំស្វែងរកណាស់ទើបបាន, បើដូនជាឃើញធ្លាក់ក្នុងទីណាមួយ ទោះជាដុំតូចក៏ដោយធំក៏ដោយ ត្រូវតែរើសយកទៅទុក ឥតមានទោសពៃរ៍អ្វីឡើយ ឲ្យតែគ្មានម្ចាស់ហួងហែងរក្សាទុក ត្រាន់នឹងប្រើប្រាស់តាមសេចក្តីត្រូវ

ការយ៉ាងណាមិញ ដូចជាកល្យាណមិត្ត ដែលរកបានដោយក្រ បើយើងបានជួបគង់ទីណាក៏ដោយ ទោះក្មេងក្តី ចាស់ក្តី មានក្រល្អអាក្រក់ក្តី គប្បីសៀកខ្លួនចូលទៅសេពគប់ចុះ ព្រោះជាទីមានប្រយោជន៍ពុំខានឡើយ ក៏យ៉ាងនោះដែរ ។

ម្យ៉ាងទៀតដូចជាដុំលាមក បើយើងឃើញសម្បុណ៌ពោរពាសទៅគង់ទីណាក៏ដោយ ទោះដុំតូចក្តីធំក្តី មិនមានម្ចាស់គេហួងហែងក៏ដោយ កុំលូកដៃទៅចាប់ឲ្យសោះ តែចាប់មុខជាពិបាកលាងទឹកមិនខានទេ; សេចក្តីនេះយ៉ាងណាជាដូចជាបាបមិត្ត ទោះបីមានសម្បុណ៌គគោក តូច, ធំ, ចាស់, ក្មេង, មានក្រ ល្អ អាក្រក់ប្រិនយ៉ាងណាក៏ដោយ កុំគប្បីប៉ុនខ្លួនទៅកៀតឲ្យសោះ តែប្រថុយចូលទៅសេពគប់មុខជាទីក្អាក់ខ្លួនមិនខានទេ ក៏យ៉ាងនោះដែរ ។

ព្រះសម្ពុទ្ធជាម្ចាស់ កាលដែលទ្រង់ប្រៀនប្រដៅអានន្ទត្ថេរជាមិត្តក៏សត់កម្រែរបស់ព្រះអង្គ ប៉ុន្តែជាភិក្ខុមានៈរើសរូស ទ្រង់សំដែងព្រាប់ថា:

ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ

សេចក្តីថា: (ម្នាលអានន្ទៈ) បុគ្គលមិនត្រូវសេពគប់ បាបមិត្តឬបុរសថយថោកទេ គប្បីសេពគប់តែកល្យាណមិត្ត ឬបុរសខ្ពង់ខ្ពស់ ។

ពុទ្ធភាសិតប៉ុណ្ណោះបញ្ជាក់ឲ្យឃើញថា ព្រះសម្ពុទ្ធទ្រង់បដិសេធបាបមិត្តនិងបុរសថយថោកថោលស្រឡះ មិនឲ្យសេពគប់ដោយដាច់ខាត ថាឲ្យសេពគប់តែនឹងកល្យាណមិត្តឬបុរសខ្ពង់ខ្ពស់ជាដរាប ។

អស់លោកអ្នកសប្បុរសទាំងឡាយ ! កាលណាបើយើងមានកល្យាណមិត្តបរិបូណ៌ហើយ ប្រាកដជាបានសេចក្តីសុខដោយពិត ឬក៏អាចធ្វើកិច្ចហួសវិស័យដែលជនតិចគ្នា ធ្វើឲ្យសម្រេចបានដោយកម្រនោះ ឲ្យបានសម្រេចតាមសម័យនិយមពុំខាន ។

សំដែងមកអំពី « សុខកថា » សន្មត់ថាចប់តែប៉ុណ្ណេះ ឃរំ ។

សូមឲ្យជាគជ័យសិរីវុឌ្ឍិភាពគ្រប់ប្រការ កើតមានដល់អស់លោកអ្នកពុទ្ធមាមកៈអ្នកស្តាប់ទាំងឡាយ អស់កាលជានិច្ចរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ! ។

ចប់